ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

កិច្ចប្រជុំរួមប្រចាំខែកញ្ញា ឆ្នាំ២០២០
ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង ម៉ូលី

នារសៀលថ្ងៃព្រហស្បតិ៍ ១៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០២០ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង ម៉ូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញជាអធិបតី ដឹកនាំកិច្ចប្រជុំរួមប្រចាំខែកញ្ញា ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ នាយក-នាយករងខុទ្ទល័យ អគ្គលេខាធិការ-រង ប្រធាន-អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យសរុបចំនួន៥៤ រូប(ស្ត្រី១១រូប) ដើម្បីពិនិត្យលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីរបៀបវារៈនៃកិច្ចប្រជុំ ព្រមទាំងបញ្ហាផ្សេងៗ។ បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម **ឈឹម ឃិនដារ៉ែត** អគ្គលេខាធិការ ធ្វើបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែកញ្ញា ឆ្នាំ២០២០ និងលើកទិសដៅសម្រាប់ខែតុលា។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម ឃិនដារ៉ែត** អគ្គលេខាធិការ បានធ្វើបទបង្ហាញដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

១) សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
២) សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
៣) បញ្ហាប្រឈមផ្សេងៗ។
៤) ជំហានបន្តសម្រាប់ខែបន្ទាប់។

ជាកិច្ចបន្តនៅក្នុងរបៀបវារៈទី២ ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូនឯកឧត្តម **ង៉ា ថលា** អនុប្រធាន អ.ជ.ប.ជ.អ ធ្វើបទបង្ហាញអំពី ៖ ការរៀបចំវិធីសាស្ត្រ នៃការដាក់បញ្ចូលសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅថ្នាក់ឃុំ/សង្កាត់។ ដោយទទួលបានការអនុញ្ញាត ឯកឧត្តម **ង៉ា ថលា** បានរាយការណ៍ជូនអង្គប្រជុំដូចតទៅ៖

១) ផែនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ :

- **វិធីសាស្ត្រ**

- កសាងទំនាក់ទំនង ផ្ទង់គំនិត និងថាមពល
- ឃុំ សង្កាត់លើកគម្រោងផែនការឆ្លើយតបនឹងការរាលដាលជំងឺអេដស៍នៅក្នុងផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគ ឃុំ/សង្កាត់ ដើម្បីសម្រេចគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ តាមរយៈការបណ្តុះបណ្តាលនៅថ្នាក់ស្រុក។
- ភាពជាម្ចាស់ការរបស់រដ្ឋបាលស្រុក ឃុំ/សង្កាត់ (Local Ownership)
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាអ្នកសម្របសម្រួល (Coaching)
- បរិយាប័ន្ន ត្រូវលើកកម្ពស់ស្ថានភាពរបស់បុគ្គលនិងក្រុមនានា ក្នុងការចូលរួម និងទទួលផលពីសកម្មភាពនានារបស់សង្គមដោយគ្មានការរើសអើង។
- ចូលរួមធ្វើការងារក្នុងបរិយាកាសសប្បាយរីករាយជាមួយសហគមន៍ដោយប្រុងប្រយ័ត្ន។

- **ធាតុចូលទាំង៦ នៃការធ្វើផែនការ**
  - ហេតុអ្វីបានជា ឃុំ/សង្កាត់ ត្រូវធ្វើការងារអេដស៍?
  - នរណាជាប្រជាជនគោលដៅ?
  - នរណាជាប្រជាជនគោលដៅ មានចំនួនប៉ុន្មាន?
  - នរណាខ្លះមានតួនាទីក្នុងការងារអេដស៍?
  - តើត្រូវរៀបចំផែនការសកម្មភាពយ៉ាងដូចម្តេច?
  - តើត្រូវធ្វើសកម្មភាពអ្វីខ្លះជាមួយប្រជាជនគោលដៅ?

២) ជំហានសម្រាប់អនុវត្តន៍ សជណ២១៣ នៅថ្នាក់ខេត្ត ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ៖

- វិធានការទី១: គ្រប់ឃុំ សង្កាត់ ទូទាំងខេត្ត លើកផែនការ និងថវិកាសម្រាប់ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់។
- វិធានការទី២: ស្នើឱ្យមន្ទីរផែនការ និងមន្ទីរសុខាភិបាល ជួយសម្របសម្រួលឱ្យអ្នកផ្តុំកមេរោគអេដស៍ ទទួលបណ្ណសមធម៌។
- វិធានការទី៣: មន្ទីសុខាភិបាលត្រូវរៀបចំឱ្យមានផែនការ និងថវិកា ការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- វិធានការទី៤: ពិនិត្យលទ្ធភាព ត្រៀមផ្តល់ថវិកា ហិរញ្ញប្បទានដល់សង្គមស៊ីវិល ឬជូលមន្ត្រី កិច្ចសន្យា សម្រាប់ធ្វើការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងករណីចាំបាច់។

បន្ទាប់មក កិច្ចប្រជុំបានដំណើរការបន្តនៅក្នុងរបៀបវារៈទី៣ ក្នុងនោះឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

១) សូមកោតសរសើរចំពោះ មន្ត្រីរាជការ ដែលបានខិតខំប្រឹងប្រែងបំពេញការកិច្ច ក្នុងអំឡុងពេលជំងឺកូវីដ១៩ កំពុងរាតត្បាតនេះ។

២) ការអនុវត្ត សជណ២១៣ ជាចំណុចសំខាន់ ការធ្វើនៅខេត្តកំពង់ស្ពឺជាការចាប់ផ្តើម ដែលយើងត្រូវយកទៅអនុវត្តនៅខេត្តផ្សេងៗទៀត។ ខេត្តមួយចំនួនធំ មិនទាន់បានយល់ដឹងពីខ្លឹមសារនៃសជណ២១៣នេះទេ ប៉ុន្តែខេត្តមួយចំនួនក៏បានអនុវត្តរួចហើយ។ សជណ២១៣ ជាក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្ត។ ត្រូវផ្តល់ សជណ២១៣ ជូនឯកឧត្តមអភិបាលខេត្ត ដើម្បីឱ្យអនុវត្តការងារអេដស៍។

៣) ត្រូវណែនាំ ដល់ថ្នាក់ខេត្ត ថ្នាក់ស្រុក ថ្នាក់ឃុំ ឱ្យអនុវត្តនូវ ៖ ទី១) រៀបចំបង្កើតគណៈកម្មាធិការអេដស៍ ទី២) ណែនាំឱ្យបញ្ចូលផែនការអភិវឌ្ឍ ឃុំ/សង្កាត់។

៤) ឯកឧត្តម លោកជំទាវ អនុប្រធាន ដែលមានការទទួលខុសត្រូវជាមួយនឹងខេត្ត ត្រូវត្រៀមចុះតាមខេត្តនានា ដើម្បីធ្វើបទឧទ្ទេសនាម ដែលតម្រូវឱ្យមាន ឯកសារ ដូចជា ៖ សជណ២១៣ អនុក្រឹត្យលេខ១៩៣ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ហៅថា **វិមជ្ឈការ** និងសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គម ឃុំ/សង្កាត់ (សៀវភៅក្រហម)។

៥) ត្រូវមានសេចក្តីប្រកាសអន្តរក្រសួងលេខ១៨២ ស្តីអំពីល័ក្ខខ័ណ្ឌហិរញ្ញវត្ថុ ល័ក្ខខ័ណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុ មានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលខេត្ត សម្រាប់អនុវត្តមុខនាទីគ្រប់គ្រង និងផ្តល់សេវា។

៦) ឯកឧត្តមទេសរដ្ឋមន្ត្រី បានចេញនូវសេចក្តីណែនាំដល់ ឯកឧត្តម លោកជំទាវ ដោយបែងចែកក្រុមការងារឱ្យ ទទួលខុសត្រូវក្នុងការសម្របសម្រួលសិក្ខាសាលាស្តីពី ការអនុវត្តសេចក្តីជូនដំណឹងលេខ២១៣ សជណ.សស ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅស្រុកទាំង៨ នៃខេត្តកំពង់ស្ពឺ។

៧) ឯកឧត្តមទេសរដ្ឋមន្ត្រី បានណែនាំដល់អគ្គលេខាធិការ ឱ្យរៀបចំជាកំណត់ចំណាំ (Memo) តើមានឯកសារអ្វីខ្លះ ដើម្បីឱ្យក្រុមការងារទាំង៨ក្រុម យកទៅអនុវត្តក្នុងវគ្គបណ្តុះបណ្តាលនេះ និងឱ្យរៀបចំសេចក្តីជូនដំណឹងដល់អភិបាលខេត្តកំពង់ស្ពឺ ដើម្បីធ្វើអន្តរាគមន៍ និងសម្របសម្រួលដល់ការរៀបចំវគ្គបណ្តុះបណ្តាលក្រុមប្រឹក្សា ថ្នាក់ឃុំ/សង្កាត់ នៅក្រុង ស្រុកទាំង៨ នៃខេត្តកំពង់ស្ពឺ។

៨) ស្នើសុំឱ្យអភិបាលស្រុក ដឹកនាំការងារ និងបញ្ចូលសកម្មភាព ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ចូលទៅក្នុងផែនការអភិវឌ្ឍន៍ ឃុំ/សង្កាត់។

៩) វាយតម្លៃអំពីសភាពការណ៍ ឬស្ថានភាពជំងឺអេដស៍នៅក្នុងស្រុក ដែលមានផ្ទុកមេរោគអេដស៍។

នៅទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការងារឱ្យបានកាន់តែប្រសើរឡើង។ លើសពីនេះទៅទៀត ត្រូវយកលទ្ធផលជាធំ រកឱ្យឃើញករណីឆ្លងថ្មី និងទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ បើសង្ស័យត្រូវធ្វើការណែនាំឱ្យធ្វើតេស្តឈាម ធ្វើការព្យាបាលដោយប្រើថ្នាំ និងការការពារដោយប្រើស្រោមអនាម័យ យើងទាំងអស់គ្នាត្រូវប្តេជ្ញាអនុវត្តការងារឱ្យទទួលបានជោគជ័យ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង៤:៥៥ នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃសុក្រ ១៥កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០

បានឃើញ និងឯកភាព	អ្នកធ្វើកំណត់ហេតុ
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ	នាយកខុទ្ទកាល័យ
អៀង-មួលី	ស៊ុត-ថងជាន់